# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jan-2013, 16:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងទម្រង់នៃការចូលរួម និងការថតវីដេអូ នៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះតុលាការកំពូល: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រីម, ប្រធាន | អៀង សារី |
| លោក Andrew CAYLEY | ចៅក្រម C. N. JAYASIINGHE | |
| | ចៅក្រម សោម សិរីវឌ្ឍ | មេធាវីការពារក្តីជនជាប់ចោទ: |
| | ចៅក្រម A. KLONOWIECKA-MILART | លោក អាង ឧត្តម |
| | ចៅក្រម ម៉ុង មុន្នីចរិយា | លោក Michael G.KARNAVAS |
| | ចៅក្រម Florence MUMBA | |
| | ចៅក្រម យ៉ា ណារិន | |

**សហមេធាវីនាំមុខតំណាងដើមបណ្តឹង**
**រដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

## I. សេចក្ដីផ្ដើម

១- នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ មេធាវីការពារក្ដី អៀង សារី ("មេធាវីការពារក្ដី") បានដាក់បណ្ដឹងសាទុក្ខភ្លាមមួយ ("បណ្ដឹងសាទុក្ខ") ប្រឆាំងនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធលើសំណើរបស់ពួកគេថា អៀង សារី ("ជនជាប់ចោទ") ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់សវនាការ ជាជាងពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងការច្រានចោលសំណើរបស់មេធាវីការពារក្ដីបន្ថែមមួយទៀត ដែលស្នើសុំថតជនជាប់ចោទជាវីឌីអូ ខណៈនៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ ("សេចក្ដីសម្រេចដែលរងការជំទាស់")[1]។ មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") (ក) អនុញ្ញាតឱ្យជនជាប់ចោទមានវត្តមាននៅក្នុងបន្ទប់សវនាការ ឬប្រសិនបើច្រានចោលសំណើនេះ (ខ) បង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូងឱ្យបង្ហាញរូបភាពលោក អៀង សារី នៅក្នុងកញ្ចក់អេក្រង់ទូរទស្សន៍ក្នុងសាលសវនាការ ឬបង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូងឱ្យអនុញ្ញាតឱ្យថតជនជាប់ចោទជាខ្សែវីឌីអូ នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[2]។

២- មេធាវីការពារក្ដីអះអាងដោយពឹងផ្អែកលើវិធាន១០៤(៤)(ក), ១០៤(៤)(ខ) និង ១០៤(៤)(ឃ) ជាទឡ្ហីករណ៍សម្រាប់ការទទួលយកនៃបណ្ដឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្ដឹងសាទុក្ខនេះ មិនអាចទទួលយកបានយ៉ាងជាក់ស្ដែងក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ដោយឈរលើមូលដ្ឋាននេះ និងដើម្បីជាផលប្រយោជន៍នៃការសន្សំសំចៃរបស់តុលាការ និងដោយពុំបានផ្ដល់នូវសម្បទាននៃអង្គសេចក្ដី សហព្រះរាជអាជ្ញានឹងកំហិតទៅលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនត្រឹមតែភាពអាចទទួលយកបានប៉ុណ្ណោះ។

---

[1] **E1/147.1** ប្រតិចារឹក, ៤ ធ្នូ ២០១២ ត្រង់ផ្នែក២៧-២៨។

[2] **E238/9/1/1** បណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឱ្យគាត់ថតជាវីដេអូនៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ, ១៩ ធ្នូ ២០១២ ត្រង់កថាខណ្ឌ VI។

## II. ប្រវត្តិនីតិវិធី

៣- ជនជាប់ចោទពេលនេះមានអាយុ៨៧ឆ្នាំហើយ ហើយបានទទួលការពិនិត្យវេជ្ជសាស្ត្រជាលើកដំបូងតាមដំណើរការរបស់ អ.វ.ត.ក នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧។ នៅពេលនោះ គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យទៅលើរោគសញ្ញាខាងផ្លូវកាយមួយចំនួន ដូចជា របួសក្នុងកោសិកាខ្នងផ្នែកខាងក្រោម ភាពមិនប្រក្រតីខាងប្រព័ន្ធផ្ដោកនោម និងស្ថានភាពប្រព័ន្ធសរសៃឈាមបេះដូង[3]។ ខណៈដែលស្ថានភាពរបស់គាត់កាលពីពេលនោះមានភាពនឹងនរ គេបានធ្វើការកត់សំគាល់ថា ការណ៍នេះអាចនឹងប្រែប្រួលក្នុងពេលណាមួយ។ ដូច្នេះ ជនជាប់ចោទត្រូវបានដាក់ឲ្យស្ថិតក្រោម "ការតាមដានយ៉ាងជិតដល់"[4] ដែលបានបន្តរហូតតាំងពីពេលនោះមក។

៤- បន្ទាប់ពីមានសំណើរបស់មេធាវីការពារក្ដីដែលសុំឲ្យធ្វើការជំនុំជម្រះតែកន្លះថ្ងៃ ដោយសារតែមូលហេតុខាងសុខភាពរបស់ជនជាប់ចោទ[5] អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងសាស្ត្រាចារ្យ John Campbell ដែលជាអ្នកជំនាញអន្តរជាតិខាងថែទាំមនុស្សចាស់ ដើម្បីពិនិត្យ អៀង សារី។ បន្ទាប់ពីការពិនិត្យដែលបានធ្វើឡើងនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ សាស្ត្រាចារ្យ Campbell បានរកឃើញថា ខណៈដែលជនជាប់ចោទទទួលរងជម្ងឺស្ទះសរសៃឈាមក្នុងបេះដូង ជម្ងឺឈឺខ្នងកាន់តែចុះខ្សោយ និងភាពញ័រកញ្ជ្រាប់នៃការបត់ជើងតូចកម្រិតពីរ ដែលនាំទៅដល់ការរាំងស្ទះក្រពេញប្រូស្តាត ប៉ុន្តែគាត់មិនមានភាពអន់ថយខាងការចងចាំ ឬការយល់ដឹងទេ[6]។ មេធាវីការពារក្ដីមិនបានតវ៉ាអំពីការរកឃើញទាំងនេះឡើយ[7]។

៥- នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ វេជ្ជ. លឹម ស៊ីវុត្ថា ជាវេជ្ជបណ្ឌិតមួយរូបដែលព្យាបាលជនជាប់ចោទ ត្រូវបានអញ្ជើញមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីរាយការណ៍អំពីលទ្ធភាពរបស់

---

[3] **A100/5** របាយការណ៍, ១៨ មករា ២០០៨ ត្រង់ទំព័រ១-៣។

[4] **B15/1** របាយការណ៍របស់ជនជាប់ចោទ, ៩ តុលា ២០០៨ ត្រង់ទំព័រ៤-៥។

[5] **E20** ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្ដីរយៈពេលកន្លះថ្ងៃ, ១៩ មករា ២០១១។

[6] **E62/3/5** របាយការណ៍អ្នកជំនាញថែទាំមនុស្សចាស់ លោក អៀង សារី ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១១ រៀបចំឡើងជាការឆ្លើយតបទៅនឹងដីការចាត់តាំងជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង, ១៣ មិថុនា ២០១១។

[7] **E110** ដីកាកំណត់កាលបរិច្ឆេទសវនការ ស្ដីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ, ១២ សីហា ២០១១, ទំពរ២។

ជនជាប់ចោទក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[8]។ គាត់បានផ្តល់អនុសាសន៍ឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធី តាមមធ្យោបាយចក្ខុទស្សន៍/សោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាកន្លែងដែលវេជ្ជបណ្ឌិតព្យាបាលអាច "តាមដានទៅលើស្ថានភាពសុខភាពរបស់គាត់"[9]។

៦- អៀង សារី ត្រូវបានពិនិត្យជាថ្មីម្តងទៀតដោយសាស្ត្រាចារ្យ Campbell និងអ្នកជំនាញពីររូបទៀត កាលពីចុងខែសីហា ឆ្នាំ២០១២។ នៅក្នុងរបាយការណ៍របស់ពួកគាត់ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ អ្នកជំនាញបានបញ្ជាក់អះអាងថា ជនជាប់ចោទនៅតែមានសម្បទាទាំងខាងរាងកាយ និងស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ[10]។

៧- នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ អៀង សារី បានចូលសម្រាកនៅមន្ទីរពេទ្យដោយលើកឡើងអំពីបញ្ហាហេវហត់អស់កម្លាំង ទន់ខ្សោយ និងបង្អក់ខ្យល់[11]។ គាត់សម្រាកនៅមន្ទីរពេទ្យអស់រយៈពេលប្រហែលពីរខែ។

៨- នៅថ្ងៃទី៥ និងទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ ជនជាប់ចោទបានទទួលការពិនិត្យសុខភាពជាលើកទីបីដោយសាស្ត្រាចារ្យ Campbell ហើយបានពិនិត្យឃើញមានរោគសញ្ញានៃជម្ងឺវិលមុខវ្វិលភ្នែក ... 

[8] **E197** លិខិត, កម្មវត្ថុ: "លិខិតអញ្ជើញជូនចំពោះលោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា ប្រធានផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដើម្បីមកពន្យល់នៅបន្ទប់សាលសវនាការនៅពេលព្រឹក ថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២", ២១ ឧសភា ២០១២។

[9] **E1/75.1** ប្រតិចារឹក, ២៣ ឧសភា ២០១២, ត្រង់ទំព័រ៩។

[10] **E11/86/1** របាយការណ៍វេជ្ជសាស្ត្រស្តីពីលោក អៀង សារី, ៣ កញ្ញា ២០១២ ត្រង់កថាខណ្ឌ៤១-៤២។

[11] **E1/125.1** ប្រតិចារឹក, ២១ កញ្ញា ២០១២ ត្រង់ទំព័រ១២។

[12] **E238/4** របាយការណ៍អ្នកជំនាញស្តីពី លោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238), ៦ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី៩។

ឃុំខ្លួនខាងក្រោមសាលសវនាការបានពេញលេញ ព្រមទាំងឲ្យសម្របខ្លួន[13] ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[14]។

៩- នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមួយ ដោយរកឃើញថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[15]។ ក្នុងសេចក្តីសម្រេចនេះក៏បានកត់សំគាល់ផងដែរថា ការចុះខ្សោយកម្លាំងជាទូទៅរបស់ជនជាប់ចោទបានធ្វើឲ្យមានការផ្អាកដោយផ្ទាល់នូវដំណើរការសវនាការមួយផ្នែក ឬទាំងស្រុងរយៈពេល ១២ថ្ងៃហើយ[16] និងថាបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនៅតែអាចឲ្យមេធាវីការពារក្តី និងអង្គភាពពេទ្យរបស់ អ.វ.ត.ក ចេញចូលបានគ្រប់ពេល[17] និងថាបើដូច្នេះជាកន្លែងល្អបំផុតសម្រាប់សេចក្តីត្រូវការខាងសុខភាពបច្ចុប្បន្នរបស់ អៀង សារី[18]។

១០- នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យ អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយច្រានចោលសំណើរបស់មេធាវីការពារក្តីដែលស្នើសុំថតវីឌីអូ អៀង សារី[19]។ សេចក្តីសម្រេចនោះ ត្រូវបានធ្វើឡើងឈរលើរបាយការណ៍វេជ្ជសាស្ត្រមួយពីគ្រូពេទ្យព្យាបាលជនជាប់ចោទ ដែលបានស្នើសុំការ "អនុញ្ញាតឲ្យជនជាប់ចោទតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដែលនឹងអនុញ្ញាតឲ្យវេជ្ជបណ្ឌិតអាចតាមដានពីស្ថានភាពរាងកាយរបស់ អៀង សារី[20]"។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សំគាល់អំពីមតិរួមមួយរបស់អ្នកជំនាញខាងវេជ្ជសាស្ត្រដែលថា ជនជាប់ចោទអាចចូលរួមបានល្អប្រសើរពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការរបស់គាត់ដោយសារ"កាលៈទេសៈផ្នែករាងកាយរបស់គាត់" "ការលំបាកផ្សេងៗ" ដែលរួម

---

[13] **E1/142.1** ប្រតិចារឹក, ៨ វិច្ឆិកា ២០១២ ត្រង់ទំព័រ១៦-១៧។

[14] **E238/4** របាយការណ៍អ្នកជំនាញស្តីពី លោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238), ៦ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី២១។

[15] **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២។

[16] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៣៥។

[17] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៣៦។

[18] *ដដែលដូចខាងលើ* ។

[19] **E1/147.1** ប្រតិចារឹក, ៤ ធ្នូ ២០១២ ត្រង់ទំព័រ១៧-២០, ២៧-២៨។

[20] *ដដែលដូចខាងលើ,* ទំព័រ១៨។

មានទាំងហានិភ័យនៃ "ការពន្យារពេលជាដុំកំភួនទៅលើការជំនុំជម្រះ" ដែលពាក់ព័ន្ធនឹងការនាំខ្លួន អៀង សារី មកកាន់បន្ទប់សវនាការ និងថាវេជ្ជបណ្ឌិតដែលមើលថែទាំសុខភាពរបស់គាត់ អាចតាមដានបានយ៉ាងល្អប្រសើរពីសុខភាពរបស់គាត់ ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[21]។ មេធាវីការពារក្តី ត្រូវបានអនុញ្ញាតឱ្យមានសមាជិកនៃបុគ្គលិកម្នាក់ពីក្រុមរបស់ខ្លួន នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនោះ ដើម្បីផ្តល់នូវកង្វល់ណាមួយពីស្ថានភាពសុខភាពរបស់ អៀង សារី ជូនទៅគ្រូពេទ្យព្យាបាល[22]។ មេធាវីការពារក្តីបានធ្វើហួសពីសិទ្ធិនោះ ហើយញ៉ាំងឱ្យមានការព្រមានមួយពីអង្គជំនុំជម្រះសាលាដំបូងចំពោះទង្វើខុសឆ្គងនោះ[23]។

១១- នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យមានការសន្និដ្ឋានបន្ថែមលើបញ្ហានៃការថតខ្សែអាត់សម្លេង និងវីឌីអូ ដើម្បីសម្រេចជាចុងក្រោយលើបញ្ហានេះ ("ការបង្គាប់ឱ្យដាក់សារណាបន្ថែម")[24]។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ មេធាវីការពារក្តីបានដាក់សារណារបស់ខ្លួន[25] ដោយតវ៉ាថា សិទ្ធិថតខ្សែអាត់សម្លេង/វីឌីអូ របស់ អៀង សារី មានជាប់មកជាស្រេចក្នុងសិទ្ធិជាមូលដ្ឋានរបស់គាត់ក្នុងការត្រៀមរៀបចំការការពារខ្លួនគាត់ បើតាមការអះអាង គឺរួមមានទាំងសិទ្ធិក្នុងការថតខ្សែអាត់សម្លេង/វីឌីអូ"[26]។

១២- នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២[27] សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋាននេះដោយអះអាងថា មេធាវីការពារក្តីខកខានមិនបានលើកអំណះអំណាងអំពីសិទ្ធិតាមផ្លូវច្បាប់ណាមួយក្នុងការថតខ្សែអាត់សម្លេង/វីឌីអូ អៀង សារី ទេ និងថាទម្លាប់នៃការអនុវត្តដូច្នេះ

[21] *ដដែលដូចខាងលើ,* ទំព័រ១៨-១៩, ២៧។

[22] *ដដែលដូចខាងលើ,* ទំព័រ២៧។

[23] **E254** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការបង្គាប់ឱ្យដាក់សារណា, ១២ ធ្នូ ២០១២។

[24] **E254** ការបង្គាប់ឱ្យដាក់សារណា, ១២ ធ្នូ ២០១២។

[25] **E254/1** សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឱ្យថតខ្សែអាត់សំឡេង និង/ឬ វីដេអូរបស់គាត់ នៅក្នុងបន្ទប់ឃុំខ្លួន[ខាងក្រោមសាលសវនាការ], ១៤ ធ្នូ ២០១២។

[26] *ដដែលដូចខាងលើ,* សេចក្តីផ្តើម។

[27] **E254/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សារណារបស់ អៀង សារី ស្តីពីច្បាប់ដែល អនុញ្ញាតឱ្យគាត់ថតខ្សែអាត់សម្លេង និង/ឬ វីឌីអូ នៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ", ២១ ធ្នូ ២០១២។

ត្រូវបានហាមឃាត់តាមវិធានផ្ទៃក្នុង[28]។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់ធ្វើសេចក្តីសម្រេចនៅឡើយ។

## III. បណ្តឹងសាទុក្ខមិនអាចទទួលយកបានយ៉ាងជាក់ស្តែង

### *ក. បណ្តឹងសាទុក្ខមិនអាចទទួលយកបានតាមវិធាន១០៤(៤)(ក)*

១៣- វិធាន១០៤(៤)(ក) អនុញ្ញាតតែបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹង "សេចក្តីសម្រេចដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ប៉ុណ្ណោះ។ នៅត្រង់កថាខណ្ឌ២៣ នៃបណ្តឹងសាទុក្ខ មេធាវីការពារក្តីអះអាងថា ការបង្គាប់ឲ្យ អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការគឺជាការបញ្ចប់កិច្ចដំណើរការនីតិវីដោយហេតុថា "សម្រាប់រូបគាត់ [អៀង សារី] កិច្ចដំណើរការនីតិវិធីទាំងនេះក្លាយជាឥតន័យ"[29]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អំណះអំណាងនេះគឺបានផ្អែកលើវិធានការបកស្រាយមិនត្រឹមត្រូវនៃវិធាន១០៤(៤)(ក)។ តក្កវិជ្ជានៃអំណះអំណាងនេះ គឺនឹងត្រូវទទួលយកបណ្តឹងសាទុក្ខណាមួយទៅតាមតែការនឹកឃើញរបស់ជនជាប់ចោទប៉ុណ្ណោះតាមរយៈការដាក់ជំនួសនូវជំនឿអត្តនោម័តសុទ្ធសាធ និងគ្មានមូលដ្ឋានរបស់មេធាវីការពារក្តីសម្រាប់លក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់សត្យានុម័ត។

១៤- អំពីបញ្ហាថាតើ អៀង សារី *បច្ចុប្បន្ននេះ* មានសម្បទាចូលរួមសវនាការ ឬមួយយ៉ាងណានោះ គឺត្រូវបានដោះស្រាយយ៉ាងទូលំទូលាយដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ[30]។ ខណៈដែលបណ្តឹងសាទុក្ខកំពុងដំណើរការទៅមុខ ដោយមានអំណះអំណាងមួយចំនួនពាក់ព័ន្ធនឹងស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទ ដែលមានការខ្វែងគ្នាគួរឲ្យកត់សម្គាល់ ពីការវាយតម្លៃបច្ចុប្បន្នទាំងរបស់គ្រូពេទ្យព្យាបាល[31] និងទាំងរបស់អ្នកជំនាញដែលបានតែងតាំងដោយអង្គជំនុំជម្រះ[32] ដែលការ

---

[28] *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ២។

[29] **E238/9/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យគាត់ថតជាវីដេអូនៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ, ១៨ ធ្នូ ២០១២ ត្រង់កថាខណ្ឌ២៣។

[30] ឯកសារលេខ **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនចាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ត្រង់ទំព័រទី១៥។

[31] ឯកសារលេខ **E11/86/L** របាយការណ៍, ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២។

អះអាងបែបនោះមិនអាចផ្តល់នូវទម្ងន់ជាភស្តុតាងវេជ្ជសាស្ត្របានឡើយ[33]។ ទាក់ទងទៅនឹងភស្តុតាងវេជ្ជសាស្ត្រដែលកំពុងជំទាស់នេះ ការជឿជាក់ជាសត្យានុម័តតែមួយរបស់សហមេធាវីការពារក្តីដែលថា ការចូលរួមរបស់ អៀង សារី ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ "មិនមានន័យ" នោះ គឺវាមិនអាចទាក់ទងទៅនឹងការវាយតម្លៃណាមួយស្តីពីភាពអាចទទួលយកបាននូវបណ្តឹងសាទុក្ខមួយនេះបានឡើយ។

១៥- ករណីយុត្តិសាស្ត្រពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា វិធាន១០៤(៤)(ក) ត្រូវតែជាកម្មវត្ថុនៃ "ការបកស្រាយសមហេតុផល" ស្របតាមស្មារតីនៃគោលបំណងរបស់វិធាននេះ ដើម្បីធានានូវកន្លែងមួយអំពីអត្ថិភាពនៃបណ្តឹងសាទុក្ខ បើសិនជាកិច្ចដំណើរការនីតិវិធីត្រូវ"ត្រូវបានបញ្ចប់យ៉ាងមានប្រសិទ្ធិភាព" ហើយអង្គជំនុំជម្រះមិនស្ថិតក្នុងគោលជំហរដើម្បី "ចេញសាលក្រមលើអង្គសេចក្តី"[34]។ នៅទីនេះ គេគ្មានអំណះអំណាងដែលអាចបញ្ជោតបានថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់យ៉ាងមានប្រសិទ្ធិភាពនូវកិច្ចដំណើរការនីតិវិធីឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា កិច្ចដំណើរការនីតិវិធីគួរតែបន្តប្រឆាំងនឹង អៀង សារី ដោយឲ្យគាត់ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

១៦- នៅក្នុងការលះបង់ចោលបណ្តឹងសាទុក្ខមួយពីមុនដែលបានដាក់ដោយ អៀង សារី អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានច្រានចោលអំណះអំណាងនានាដែលថា វិធាន១០៤(៤)(ក) អនុញ្ញាតឲ្យដាក់បណ្តឹងសាទុក្ខលើសេចក្តីសម្រេចនានាដែល *នឹងបណ្តាលឲ្យមាន* មោឃភាពដល់កិច្ចដំណើរការនីតិវិធី *បើ* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្សេងពីនេះ - និយាយម្យ៉ាងទៀត កាលណាមោឃភាពដល់កិច្ចដំណើរការនីតិវិធី គ្រាន់តែអាចជាបញ្ហាអាទិភាពប៉ុណ្ណោះ[35]។ បណ្តឹងសាទុក្ខបច្ចុប្បន្ន

[32] **E238/4** របាយការណ៍អ្នកជំនាញស្តីពី លោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238), ៦ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី២១។

[33] *រដ្ឋអាជ្ញា ទល់នឹង Strugar*, សំណុំរឿងលេខ IT-01-42-A, សាលដីកាលើបណ្តឹងសាទុក្ខ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨, ត្រង់កថាខណ្ឌទី២១។

[34] **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៣ ធ្នូ ២០១១ ត្រង់កថាខណ្ឌ១៥។

[35] ឯកសារលេខ **E95/8/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី ៨-៩។

នេះបានស្វែងរកនូវការជំរុញឲ្យមានការរមួលដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងវិធាន ១០៤(៤)(ក) - ដែលថា គេត្រូវកំណត់កិច្ចដំណើរការនីតិវិធី ពីព្រោះថា ដោយផ្ទុយទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទគឺមិនអាចមានលទ្ធភាពចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបានទេ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ការណ៍នេះគឺមិនមានមូលដ្ឋានតាមផ្លូវច្បាប់សម្រាប់បណ្តឹងសាទុក្ខភ្លាមៗ ទៅតាមវិធាន១០៤(៤)(ក) នោះទេ។

*ខ. បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន ទៅតាមវិធាន១០៤(៤)(ខ) បានទេ*

១៧- នៅត្រង់កថាខណ្ឌទី២៤ នៃបណ្តឹងសាទុក្ខ មេធាវីការពារក្តីបានដាក់ជូនថា “សេចក្តីសម្រេចដែលថា អៀង សារី ត្រូវស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ គឺជាសេចក្តីសម្រេចលើការឃុំខ្លួន”[36]។ ហើយដូច្នេះ ដំណោះស្រាយទៅនឹងបណ្តឹងសាទុក្ខភ្លាមៗនោះ គឺអាចមាននៅក្នុងវិធាន ១០៤(៤)(ខ)។ ការបក ស្រាយវិធាន១០៤(៤)(ខ) នេះគឺពុំមានមូលដ្ឋាននៅក្នុងច្បាប់ទាំងស្រុង។ នៅក្នុងការអនុញ្ញាតឲ្យដាក់បណ្តឹងសាទុក្ខភ្លាមៗ ទៅនឹង “ការឃុំខ្លួនបណ្តោះអាសន្ន និងការសម្រេចឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៃវិធាន ៨២” វិធាននេះ បានយោងទៅដល់សេចក្តីសម្រេចសំខាន់ៗ ស្តីពីថាតើត្រូវឃុំខ្លួន ឬត្រូវដោះលែងជនជាប់ចោទ។ សេចក្តីសម្រេចស្តី ពីទម្រង់នៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងសវនាការ មិនអាចត្រូវបានរារាំងដូចជាសេចក្តីសម្រេចមួយស្តីពីការ ឃុំខ្លួន ឬការដោះលែងបណ្តោះអាសន្នបាននោះទេ។

១៨- វិធាន៨២ ទាក់ទងតែពីសេចក្តីសម្រេចនានាដែលស្តីពីថាតើគេត្រូវឃុំខ្លួន ឬត្រូវដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការប៉ុណ្ណោះ និងមិនបាននិយាយអ្វីសោះអំពីទម្រង់ ឬលក្ខខណ្ឌនានានៃការឃុំខ្លួនអ្វីនោះទេ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ភាសានៅក្នុងវិធាន១០៤(៤)(ខ) ទៅតាមន័យធម្មតារបស់វា គឺវាច្បាស់ណាស់ដែលមិនអនុវត្តចំពោះសេចក្តីសម្រេចដែលស្តីពីទម្រង់នៃការចូលរួមនៅពេលសវនាការ ឬពីការប្រើប្រាស់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនោះឡើយ។ សេចក្តីសម្រេចបែបដូច្នោះស្ថិតនៅក្រោមវិធាន៨១ មិនមែន

[36] ឯកសារលេខ **E238/9/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមមិនឲ្យគាត់ថតវីដេអូនៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ, ត្រង់កថាខណ្ឌទី២៤។

វិធាន៨២នោះទេ ហើយដូច្នោះ គឺវានៅក្រៅវិសាលភាពនៃបណ្តឹងសាទុក្ខភ្លាមៗដែលបានចែងនៅក្នុង វិធាន១០៤(៤)(ខ)។

១៩- សេចក្តីសង្ឃឹមរបស់មេធាវីការពារក្តីទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងការអនុញ្ញាតឲ្យមេធាវីការពារក្តី ធ្វើការថតសម្លេង ពីការប្រជុំនានាជាមួយនឹងកូនក្តីរបស់ខ្លួននៅក្នុងអំឡុងពេលនៃការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី គឺមានការភាន់ច្រឡំ[37]។ បណ្តឹងឧទ្ធរណ៍នៅក្នុង ករណីនោះស្ថិតនៅក្រោមវិធាន៧៤.៣.ច ដែលជាបទប្បញ្ញត្តិមួយផ្សេងគ្នា និងមានលក្ខណៈទូលំទូលាយ ដែលអនុញ្ញាតឲ្យដាក់បណ្តឹងឧទ្ធរណ៍នៅដំណាក់កាលមុនសវនាការលើអង្គសេចក្តីជំទាស់ទៅនឹងដីកាបង្គាប់ ឬសេចក្តីសម្រេចផ្សេងៗ "ទាក់ទងទៅនឹង" ការឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ផ្ទុយទៅវិញ វិធាន១០៤(៤)(ខ) គឺមានកម្រិតច្រើនជាងដោយគ្រាន់តែអនុញ្ញាតឲ្យដាក់បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹង "សេចក្តីសម្រេចនានាស្តីពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទៅតាមវិធាន៨២" តែប៉ុណ្ណោះ។

២០- សហព្រះរាជអាជ្ញាបានសង្កេតបន្ថែមទៀតថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានលើកឡើងដោយមេធាវីការពារក្តី គឺត្រូវបានកម្រិតចំពោះបញ្ហានៃការថតសម្លេងពីការប្រជុំនានាជាមួយនឹងជនចាប់ចោទនៅក្នុងពេលឃុំខ្លួន ហើយដូច្នេះ វាមិនបានគាំទ្រដល់ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនជាប់ចោទ ទៅតាមវិធាន៨១នោះទេ។ ទាក់ទងទៅនឹងបញ្ហាខាងក្រោយនេះ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានបដិសេធពីលើកមុនទៅលើបណ្តឹងសាទុក្ខមួយដែលដាក់ដោយ អៀង សារី ស្តីពីបញ្ហាថាតើគេតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទរូបនេះនៅក្នុងសាលសវនាការ ឬមួយយ៉ាងណា ដោយមានមូលដ្ឋាននៅលើបណ្តឹងសាទុក្ខបែបដូច្នេះ គឺវាមិនស្ថិតនៅក្រោម "យុត្តាធិការដែលមានកម្រិតសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ ទៅតាមវិធាន១០៤(៤)"[38]នោះទេ។ សហព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានថា គេត្រូវតែបដិសេធបណ្តឹងសាទុក្ខបច្ចុប្បន្ននេះចោល មកពីមូលហេតុតែមួយដូចៗគ្នាទាំងនោះ។

### *គ. បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន ទៅតាមវិធាន១០៤(៤)(ឃ) បានទេ*

[37] ដូចដែលខាងលើ កថាខណ្ឌទី២៥។

[38] ឯកសារលេខ **E130/4/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២។

២១- មេធាវីការពារក្តីបានអះអាងបន្ថែមទៀតថា "តាមរយៈសេចក្តីសម្រេចមួយចំនួន ដែលមានទំនាក់ទំនងទៅវិញទៅមក (រួមទាំងសេចក្តីសម្រេចដែលបានជំទាស់) អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយចេតនា និងពិតប្រាកដជាបន្តបន្ទាប់ចូលកិច្ចស្វែងរកយុត្តិធម៌របស់តុលាការ"[39] ហើយថា សេចក្តីសម្រេចបែបដូច្នោះត្រូវស្ថិតនៅក្រោមបណ្តឹងសាទុក្ខភ្លាមៗ ទៅតាមវិធាន១០៤(៤)(ឃ)។ ដូច្នេះហើយបានជាមេធាវីការពារក្តីបានសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តវិធាន៣៥ ចំពោះ *អង្គជំនុំជម្រះសាលាដំបូងខ្លួនឯង* - នៅក្នុងការដែលបានអនុវត្តនូវមុខងារផ្សេងៗជាតុលាការ - ដោយឈរនៅលើមូលដ្ឋានខុសនោះដែលថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកចូលក្នុងកិច្ចស្វែងរកយុត្តិធម៌របស់តុលាការ ដោយគ្រាន់តែពួកគាត់បានអនុវត្តយ៉ាងត្រឹមត្រូវនូវមុខងារតុលាការ និងបានចេញនូវសេចក្តីសម្រេចដែលរងការជំទាស់ប៉ុណ្ណោះ។

២២- វិធាន១០៤.៤.ឃ អនុញ្ញាតឱ្យដាក់បណ្តឹងសាទុក្ខភ្លាមៗជូនទៅអង្គជំនុំជម្រះតុលាការកំពូល អំពី "សេចក្តីសម្រេចលើការជ្រៀតជ្រែកចូលក្នុងកិច្ចស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះ ទៅតាមវិធាន៣៥(៦)"។ ដូចដែលអង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនដូច្នោះដែរ បណ្តឹងសាទុក្ខបែបនេះគឺអាចទទួលយកបាន "ប្រសិនបើសំណើសុំ [ជាមូលដ្ឋាន] អាចត្រូវបានកំណត់ចរិតលក្ខណៈ យ៉ាងហោចណាស់ក្នុងផ្នែកខ្លះ ថាជាសំណើសុំធ្វើការស៊ើបអង្កេតប៉ុណ្ណោះ អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងនោះ"[40]។ ដូច្នោះ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកបណ្តឹងសាទុក្ខស្តីពីសេចក្តីសម្រេចមួយដែលច្រានចោលញត្តិសុំប្តឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwight ខណៈដែល "សំណើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានយោងតិចតួចទៅលើវិធាន៣៥ នៃវិធានផ្ទៃក្នុង" និង "បានស្នើសុំឱ្យមានការស៊ើបអង្កេត អនុលោមតាមវិធាន៣៥.២" នៃការប្រជុំ ដែលបានលើកឡើងចោទប្រកាន់ *ដោយភាគីតែម្ខាង*[41]។

---

[39] ឯកសារលេខ **E238/9/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមមិនឱ្យគាត់ថតវីដេអូនៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ, កថាខណ្ឌទី២៥។

[40] ឯកសារលេខ **E137/5/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwight, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១១។

[41] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១២ និង ១៦។

២៣- ផ្ទុយទៅវិញ នៅក្នុងករណីនេះ មេធាវីការពារក្ដីមិនបានធ្វើសំណើអ្វីសោះទៅកាន់អង្គជំនុំជម្រះសាលាដំបូង ទៅតាមវិធាន៣៥នោះទេ។ សំណើដែលបានធ្វើឡើងដោយសហមេធាវីការពារក្ដី Michael Karnavas នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ មិនបានយោង ទោះជាជាក់ច្បាស់ ឬមិនជាក់ច្បាស់ក៏ដោយ ទៅវាកវិធាន៣៥ ឬមួយក៏ផលប្រយោជន៍តាមផ្លូវច្បាប់ដែលត្រូវបានការពារទៅតាមនោះឡើយ[42]។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្ដីបានលើកបញ្ជាក់ពី “ករណីយកិច្ច និងការទទួលខុសត្រូវក្នុងការការពារសិទ្ធិកូនក្ដីខ្លួន” របស់សហមេធាវីការពារក្ដីទៅវិញ[43]។ ដោយឈរនៅលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា សំណើជាមូលដ្ឋានដែលលើកឡើងពីសេចក្ដីសម្រេចដែលរងការជំទាស់ គឺមិនមែនជាសំណើមួយអនុលោមតាមវិធាន៣៥ នោះឡើយ។

២៤- លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានសម្រេចថា បណ្ដឹងសាទុក្ខដែលអនុលោមតាមវិធាន១០៤(៤)(ឃ) មិនមានបង្ហាញអំពី “ទម្រង់ករណ៍នានាដែលជាក់ស្ដែងមិនអាចយកមកអនុវត្តបានតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង”[44]។ ដូចដែលអង្គជំនុំជម្រះនេះបានសម្រេចនៅក្នុងការបដិសេធលើបណ្ដឹងសាទុក្ខមួយពីមុនរបស់មេធាវីការពារក្ដី អៀង សារី ទាក់ទងនឹងថាតើគាត់ត្រូវមានវត្តមាននៅក្នុងសាលសវនាការ ឬមួយយ៉ាងណានោះ ថា ជាក់ស្ដែងមិនអាចយកមកអនុវត្តបានទេ៖

> *គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ ដែលអាចបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនាទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងតាមអត្ថន័យនៃវិធាន៣៥ នៃវិធានផ្ទៃក្នុងឡើយ*[45]។

---

[42] ឯកសារលេខ **E1/147.1** ប្រតិចារឹក, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២, ត្រង់ទំព័រទី ១២-១៥។

[43] *ដដែលដូចខាងលើ* ត្រង់ទំព័រទី១៣។ បានយោងផងដែរទៅឯកសារលេខ **E238/9/1/1** បណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមមិនឱ្យគាត់ចតវីដេអូនៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ, កថាខណ្ឌទី១៦។

[44] ឯកសារលេខ **E137/5/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីបណ្ដឹងផិតចិត្តលោកស្រីចៅក្រម Silvia Cartwight, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១២។

[45] ឯកសារលេខ **E130/4/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ត្រង់ទំព័រទី២។

អង្គជំនុំជម្រះតុលាការកំពូល ក្រោយមកបានសម្រេចថា "ការយកវិធាន៣៥ នៃវិធានផ្ទៃក្នុង មកអនុវត្តចំពោះអំពើរបស់តុលាការ ត្រូវបានរឹតត្បិតយ៉ាងខ្លាំង"[46] ដូច្នេះហើយ "ការសម្រេចរបស់តុលាការដែលមានកំហុស គឺមិនគ្រប់គ្រាន់តាមផ្លូវច្បាប់ដើម្បីបំពេញនូវបទដ្ឋានស្របតាមវិធាន ៣៥ ឡើយ"[47]។

២៥- នៅក្នុងសេចក្តីសម្រេចផ្ទាល់មាត់របស់គាត់ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង លោកស្រីចៅក្រម Silvia Cartwight មិនបានយោងទៅវិធាន៣៥ នៃវិធានផ្ទៃក្នុង ដែលជាទស្សនៈស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬមិនបានយោងទៅដល់បញ្ហាពាក់ព័ន្ធណាមួយនោះឡើយ[48]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វាពុំមានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយ ដែលលេចធ្លោចេញមកដើម្បីបកស្រាយ និងអធិប្បាយថា សេចក្តីសម្រេចដែលរងការជំទាស់នេះជា "សេចក្តីសម្រេចដែលមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល របស់អង្គជំនុំជម្រះ អនុលោមតាមវិធាន៣៥(៦)"[49] នោះឡើយ។

### *គ. ភាពអាចអនុញ្ញាតឱ្យថតជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួន ជាខ្សែវីដេអូបាន ស្ថិតនៅក្នុងភាពកំពុងស្ថិតនៅក្នុងការរង់ចាំ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*

២៦- អំណះអំណាងទីបី នៃបណ្តឹងសាទុក្ខ គឺពឹងផ្អែកទៅលើការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង "រំលោភលើឆន្ទានុសិទ្ធិ"[50] ដោយមិនអនុញ្ញាតឱ្យពួកគេថតខ្សែវីដេអូ អៀង សារី នៅក្នុងបន្ទប់ឃុំឃាំង។ សហព្រះរាជអាជ្ញា សូមជូនជាមតិដើម្បីពិចារណាថា អំណះអំណាងទីបីនៃការប្តឹងសាទុក្ខ

---

[46] ឯកសារលេខ **E137/5/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwight, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១៣។

[47] ដដែលដូចខាងលើ ត្រង់កថាខណ្ឌទី១៣។ ដោយបានដកស្រង់ ឯកសារលេខ **E130/4/3** សេចក្តី សម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យជនជាប់ចោទមាន វត្តមានក្នុងសាលសវនាការ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២។

[48] ឯកសារលេខ **E1/147.1** ប្រតិចារឹក, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២, ត្រង់ទំព័រទី ១៧-១៩ និង ២៧-២៨។

[49] វិធាន ១០៤.៤.ឃ ។

[50] ឯកសារលេខ **E238/9/1/1** បណ្តឹងសាទុក្ខរបស់ អៀងសារី ជំទាស់ទៅនឹងសេចក្តីសំរេចផ្ទាល់មាត់របស់ អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់មិនឱ្យមានវត្តមាន នៅក្នុងបន្ទប់សវនាការនិងហាមឃាត់មិនឱ្យថតវីដេអូលើរូបគាត់ នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ, ចុះថ្ងៃទី១៨ ធ្នូ ២០១២, ត្រង់កថាខណ្ឌទី២៥។

នេះ ធ្វើឡើងលឿនពេកមិនទាន់ដល់ពេលត្រូវប្តឹងទេ ដែលហេតុដូចនេះគឺមិនអាចឱ្យទទួលយកបានទាំងស្រុងតែម្តង ដោយក្នុងពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងកំពុងតែធ្វើការពិនិត្យឡើងវិញអំពីនីត្យានុកូលភាពនៃការថតជាសម្លេង និងជាខ្សែវីដេអូនៅក្នុងកាលៈទេសៈបែបនេះ។

២៧- ក្នុងបណ្តឹងសាទុក្ខនេះ បានភ្លេចដាក់សេចក្តីយោងណាមួយទៅលើដីកាសម្រេចដែលបង្គាប់ឱ្យដាក់សារណាបន្ថែម, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ , ដែលតាមរយៈនេះ អង្គជំនុំជម្រះសាលាដំបូងបានណែនាំទៅមេធាវីការពារក្តី ឱ្យដាក់សារណាស្តីពីការធ្វើយុត្តិកម្មតាមច្បាប់សម្រាប់ការអនុញ្ញាតឱ្យថត អៀង សារី ជាសោតទស្សន៍[51]។ តាមរយៈដីកាសម្រេចនេះ អង្គជុំនុំជម្រះសាលាដំបូងក៏បានណែនាំផងដែរថា៖

> *ការធ្វើសេចក្តីសង្កេតបែបនេះណាមួយបន្ថែមទៀត អំពីស្ថានភាពរបស់ អៀង សារី ទោះបីជាផ្អែកលើការថតជាឡេង លើការថតជាវីដេអូ លើសេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ឬលើអ្វីផ្សេងពីនេះ ក៏ដោយក៏សុទ្ធតែត្រូវហាមឃាត់ទាំងអស់ លុះត្រាតែភាពអាចអនុញ្ញាតឱ្យបាននៃការអនុវត្តទាំងនេះ ត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូងរួចសិន[52]។*

អាស្រ័យហេតុនេះ ទើបអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ថា ការថតជាសោត-ទស្សន៍ណាមួយនៃជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួន គឺមិនមែនជាអំណាចសំរាប់កំណត់ថាត្រូវតែហាមឃាត់នោះទេ ប៉ុន្តែគឺវាគ្រាន់តែហាមឃាត់ក្នុងនាមជាវិធានការណ៍បណ្តោះអាសន្នមួយរហូតទល់ពេលអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិនិត្យពិចារណាលើសារណាដែលមកពីភាគីនានារួចហើយចេញជាសេចក្តីសម្រេចមួយតែប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្តី អៀង សារី បានធ្វើការឆ្លើយតបទៅនឹងដីកាសម្រេចនេះដោយបានដាក់សារណាមួយ ស្តីពីការធ្វើយុត្តិកម្មតាមផ្លូវច្បាប់នៃការថតជាសម្លេង និង/ឬ ជាវីដេអូនៅក្នុងបន្ទប់ឃុំខ្លួន កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២[53]។

---

[51] ឯកសារលេខ **E254** ដីកាបង្គាប់ឱ្យដាក់សារណា ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២

[52] *ដូចគ្នានឹងខាងលើកន្លែងដែល (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។*

[53] ឯកសារលេខ **E254/1** សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឱ្យថតខ្សែអាត់សំឡេង និងឬវីដេអូរបស់គាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ, ចុះថ្ងៃទី១៤ ធ្នូ ២០១២។

សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបទៅដីកាសម្រេចនេះ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២[54]។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញសេចក្តីសម្រេចស្ថាពរ ស្តីពីភាពអាចអនុញ្ញាតឱ្យបាននៃការថតជាសំឡេង និង/ឬ ជាវីដេអូ អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួននៅឡើយទេ បន្ទាប់ពីការដាក់សារណាទាំងនោះ។

២៨- អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់អំពីសារៈសំខាន់នៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់មូលហេតុ ធ្វើជាមូលដ្ឋានសំរាប់ការប្តឹងសាទុក្ខនៅក្នុងឱកាសជាច្រើនលើកច្រើនសារ។ អង្គជំនុំជម្រះបានសម្រេចថា ពេលវេលាសម្រាប់ប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចណាមួយ នឹងត្រូវបានបើកឱ្យធ្វើ នៅបន្ទាប់ពីមានសេចក្តីសម្រេចដោយមានបញ្ជាក់មូលហេតុជាលាយលក្ខណ៍អក្សរដែលសម្រេចបញ្ចប់ទាំងស្រុងលើសំណើនានា ប្រសើរជាងការចេញសេចក្តី សម្រេចដោយផ្ទាល់មាត់[55]។ សេចក្តីសម្រេចនេះ គឺវាបន្តពីសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលថាបណ្តឹងសាទុក្ខភ្លាមៗដែលតវ៉ាជំទាស់ចំពោះការអនុវត្តជាបណ្តោះអាសន្ន នឹងមិនទាន់ដល់ពេលទេ រហូតទាល់តែសេចក្តីសម្រេចស្ថាពរជាលាយលក្ខណ៍អក្សរត្រូវបានធ្វើឡើងលើបញ្ហានេះ។ ផ្នែកនេះនៃបណ្តឹងសាទុក្ខ អាចប្រែក្លាយទៅជាមិនចាំបាច់តទៅទៀត បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាស្ថាពរមួយស្តីពីភាពដែលអាចអនុញ្ញាតឱ្យបាននៃការថតជាសម្លេង និង/ឬជាវីដេអូ[56]។ ការគិតគូរពិចារណាអំពីការសន្សំសំចៃរបស់តុលាការគួរតែតម្រូវឱ្យមេធាវីការពារក្តី រង់ចាំសេចក្តីសម្រេចនេះ មុនពេលធ្វើបណ្តឹងសាទុក្ខស្តីពីភាពដែលអាចអនុញ្ញាតឱ្យបាននៃការថតជាវីដេអូនៅក្នុងបន្ទប់ឃុំខ្លួន។

២៩- ទម្លាប់អនុវត្តរបស់តុលាការ ICTR បានគាំទ្រដល់គោលការណ៍ដែលថាបណ្តឹងសាទុក្ខ មិនគួរទទួលពិចារណា នៅពេលដែលត្រូវបានដាក់មកជូនអង្គជំនុំជម្រះសាលាឧទ្ធរណ៍ មុនពេលដែលត្រូវដាក់

[54] ឯកសារលេខ **E254/2** “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឱ្យថតខ្សែអាត់សំឡេង និងឬវីដេអូ នៅក្នុងបន្ទប់ឃុំខ្លួនរបស់គាត់ ខាងក្រោមសាលសវនាការ”, ចុះថ្ងៃទី២១ ធ្នូ ២០១២។

[55] ឯកសារលេខ **E176/2/1/4** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសំរេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន៣៥នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៤ កញ្ញា ២០១២ ត្រង់កថាខណ្ឌទី៣០។

[56] ឯកសារលេខ **E189/2/3** សេចក្តីសំរេចលើ “បណ្តឹងសាទុក្ខរបស់ នួន ជាប្រឆាំងនឹងការបដិសេធដាក់ស្តែង ដោយមិនបានសម្រេចលើសំណើសុំឱ្យធ្វើចំណាត់ការបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ” ចុះថ្ងៃទី២៦ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី៥ ។ (ដែលសម្រេចថាបណ្តឹងសាទុក្ខត្រូវបានបដិសេធចោល ចាប់តាំងពីការចេញសេចក្តីសម្រេចជាលាយលក្ខណ៍មួយ ដែលធ្វើឱ្យបណ្តឹងសាទុក្ខមិនមានហេតុផលដើម្បីពិចារណាឡើយ)។

[57]។ ឧទាហរណ៍ដូចជា មានអង្គជំនុំជម្រះសាលាដំបូងមួយបានសម្រេចទាក់ទងទៅនឹងសំណើស្តីពីភាពអាចទទួលយកបាននៃភស្តុតាងដែលបាននិយាយថា “ញត្តិស្នើសុំមិនដល់ពេល ដើម្បីនឹងយកមកធ្វើការជំនុំជម្រះនៅឡើយទេ ហើយវានឹងត្រូវមានភាពទុំ តែនៅពេលណាដែលខាងអយ្យការទាមទារសុំឲ្យប្រើប្រាស់នូវអ្វីដែលគេហៅថា កំណត់ហេតុចម្លើយនៅក្នុងពេលឃាត់ខ្លួនតែប៉ុណ្ណោះ”[58]។ អង្គជំនុំ ជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR ក៏បានយកគោលការណ៍ស្តីពីដល់ពេលវេលាវិនិច្ឆ័យនៃបញ្ហានានាស្តីពីការធ្វើបណ្តឹងសាទុក្ខនេះមកប្រើដែរ ដែលនិយាយទាក់ទងទៅនឹងសំណើសុំរបាយការណ៍មួយដែល “អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចាត់ទុកថា ដោយហេតុថា ខាងអយ្យការមិនទាន់បានផ្តួចផ្តើមគំនិតក្នុងការធ្វើបណ្តឹងណាមួយប្រឆាំងនឹងសាក្សីទាំងនេះ និងមិនមានបំណងចង់ធ្វើ

---

[57] ជាញឹកញយ តុលាការ ICTR តែងតែប្រើពាក្យ “ទុំ” ឬ “ភាពទុំ” ដើម្បីសំដៅទៅដល់ថា នេះជាពេលវេលាសមល្មមសម្រាប់អង្គជំនុំជម្រះដើម្បីធ្វើសេចក្តីសម្រេចលើញត្តិឬបណ្តឹងសាទុក្ខ ហើយឬនៅ? ។ តុលាការ ICTY អនុវត្តតាម ផ្លូវផ្សេងទាក់ទងទៅនឹងពាក្យពេចន៍, ហើយនៅក្នុងករណីរឿងមួយមុននេះ បានច្រានចោលនូវ “ទ្រឹស្តីស្តីពីភាពទុំ,” ដែលរកឃើញថាវាមិនសក្តិសមទេ ក្នុងការនាំយកទស្សនាទានក្នុងស្រុកជាក់លាក់របស់អាមេរិកាំងមកដាក់បញ្ចូលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះឡើយ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Tihomir Blaškić*, សំណុំរឿងលេខ IT-95-14, សាលដីកាលើសំណើរបស់សាធារណៈរដ្ឋក្រូអាស៊ី ដែលស្នើឲ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងទីII ចុះថ្ងៃទី ១៨ កក្កដា ១៩៩៧ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី ២៩ តុលា ឆ្នាំ២០០៧ ត្រង់កថាខណ្ឌពីទី២២-២៤។ ក៏ប៉ុន្តែ , តុលាការ ICTY មិនបានបដិសេធចោលនូវទស្សនទានជាមូលដ្ឋានស្តីពីភាពមិនទាន់ដល់ពេលត្រូវប្តឹងទេ និងជៀសវាងការចេញសេចក្តីសម្រេចលើបញ្ហាណាមួយនៅពេលដែលបញ្ហាកំពុងតែស្ថិតនៅក្នុងការពិនិត្យពិចារណាឡើងវិញ ហើយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបញ្ហានេះ នៅមិនទាន់បានចេញនៅឡើយ។

[58] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Prosper Mugiraneza និងគូរកន.*, សំណុំរឿងលេខ ICTR-99-50-I, សេចក្តីសម្រេចលើញត្តិរបស់ *Prosper Mugiraneza* ដែលស្នើសុំឲ្យលប់ចោលនូវ កំណត់ហេតុចម្លើយនៅក្នុងពេលឃាត់ខ្លួន Custodial Statement (អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTR), ចុះថ្ងៃទី ១ តុលា ២០០៣ ត្រង់កថាខណ្ឌទី១៤។ សូមអាន ផងដែរ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora*, សំណុំរឿងលេខ ICTR-96-7-T, សេក្តីសម្រេចលពាក្យសុំអ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី ដោយរដ្ឋាភិបាលនៃប្រទេសបែលហ្ស៊ិក(អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTR), ចុះថ្ងៃទី៦ មិថុនា ១៩៩៨ ត្រង់កថាខណ្ឌទី៣ (“នៅក្នុងខណៈនេះ អង្គជំនុំជម្រះសាលាដំបូងមានការយល់ឃើញថា បញ្ហានេះមិនទាន់ទុំដើម្បីឲ្យយើងធ្វើការពិនិត្យពិចារណានៅឡើយទេ។ នេះគឺព្រោះតែការពិភាក្សាអំពីការផ្តន្ទាទោសមិនទាន់បានលេចឡើងនៅមុនពេលធ្វើការកំណត់សម្រេចអំពីថា តើត្រូវមានទោសឬមួយក៏គ្មានទោស”)។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Emannuel Bagambiki និងគូរន*, សំណុំរឿងលេខ ICTR-97-36(I), សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីវិការៈខាងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTR), ចុះថ្ងៃទី២៤កញ្ញា ១៩៩៨ តត្រង់កថាខណ្ឌទី៥ (“ដោយសារវាជាបញ្ហាបឋម អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ឃើញថា នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី បញ្ហានានាដែលទាក់ទងទៅនឹងអង្គសេចក្តីនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺមិនទាន់ដល់ពេលសម្រាប់យកមកធ្វើការពិចារណានៅឡើយទេ។ អាស្រ័យហេតុនេះ យើងនឹងកម្រិតវិសាលភាពនៃការវិភាគនៅក្នុងសេចក្តីសម្រេចនេះត្រឹមតែអំពីទំរង់នៃដីបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។”)។

ដូច្នេះនោះ សំណើរបស់ដើមបណ្ដឹងសាទុក្ខដែលស្នើសុំរបាយការណ៍ គឺមិនទាន់ដល់ពេលដើម្បីធ្វើការជំនុំជម្រះនៅឡើយទេ នៅពេលមានសេចក្ដីសម្រេចនោះ”[59]។

៣០- យុត្តាធិការរបស់តុលាការក្នុងស្រុក ដែលរួមមានទាំង ប្រទេសឥណ្ឌា ប្រទេសអាហ្វ្រិកខាងត្បូង និងសហរដ្ឋអាមេរិកផង ក៏មានទស្សទានស្ដីពីភាពដែលមិនទាន់ដល់ពេលប្ដឹងសាទុក្ខនេះដែរ ដោយបានដាក់បញ្ចូលទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ទស្សនាទានទាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារប្រឆាំងនឹងភាពមិនទាន់ដល់ពេលត្រូវធ្វើ និងការកំណត់សម្រេចដោយមិនមានការចាំបាច់ស្ដីពីបញ្ហាទាក់ទងខាងអង្គច្បាប់នានាដែលមិនស្ថិតនៅចំពោះមុខតុលាការ។ នៅក្នុងសហរដ្ឋអាមេរិក ទ្រឹស្ដីបទស្ដីពីភាពចាស់ទុំបានចែងថា “ការទាមទារណាមួយដែលមិនទាន់មានភាពចាស់ទុំដើម្បីនឹងធ្វើការជំនុំជម្រះទេ ប្រសិនបើវាពឹងផ្អែកលើព្រឹត្តិការណ៍នានាជាយថាហេតុនាពេលអនាគត ដែលមិនអាចកើតមានតាមដូចដែលបានរំពឹងទុកនោះទេ ឬតាមពិតទៅ អាចនឹងមិនកើតឡើងទាល់តែសោះ”[60]។ ប្រទេសអាហ្វ្រិកខាងត្បូង បានប្រកាន់យកនូវទស្សនាទានស្រដៀងគ្នានេះ។ តុលាការធម្មនុញ្ញនឹងមិនចេញសេចក្ដីសំរេចដោយផ្អែកលើបញ្ហាទាក់ទងនឹងរដ្ឋធម្មនុញ្ញ ដែលបានរំពឹងទុកនោះទេ ដែលបានរំពឹងទុកនោះទេ តែផ្ទុយទៅវិញធ្វើការសម្រេចលើបញ្ហាតែនៅពេលណាដែលចាំបាច់តែប៉ុណ្ណោះ[61]។ នៅប្រទេសឥណ្ឌា តុលាការកំពូលបានយកទស្សនាទានស្ដីពី “ការប្ដឹងសាទុក្ខដែលមិនទាន់ដល់ពេលត្រូវធ្វើ”មកប្រើដើម្បីច្រានចោលនូវញត្តិទាំងឡាយណា ដែលបានធ្វើឡើង

---

[59] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Aloys Simba*, សំណុំរឿងលេខ ICTR-01-76-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី២៧ វិច្ឆិកា ២០០៧ ត្រង់កថាខណ្ឌទី៣០។

[60] *ករណីរឿងក្ដីរបស់ សហរដ្ឋអាមេរិក ទល់នឹង រដ្ឋ* Texas, សំណុំរឿងលេខ 97-29, សាលដីកា, ( តុលាការកំពូលនៃសហរដ្ឋអាមេរិក, លេខ 523 U.S. 296), ចុះថ្ងៃទី៣១ មីនា ១៩៩៨ត្រង់ ៣០០ (ការដកស្រង់សំដីផ្ទៃក្នុង និងការលើកឡើងនូវសំអាងផ្សេងៗត្រូវបានបំភ្លេចចោល)។

[61] *ករណីរឿងក្ដីរបស់ សហរដ្ឋអាមេរិក ទល់នឹង* *Walter Bequinot*, សំណុំរឿងលេខ CCT/24/95, សាលដីកា (តុលាការធម្មនុញ្ញានៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី១៨ វិច្ឆិកា ១៩៩៦ ត្រង់កថាខណ្ឌទី ១២-១៣។ សូមអានផងដែរ ករណីរឿក្ដីរបស់ *Zanomzi Peter Zantsi ទល់នឹង ក្រុមប្រឹក្សារដ្ឋ និងបក្សពួក.*, សំណុំរឿងលេខ CCT/24/94, សាលដីកា (តុលាការធម្មនុញ្ញានៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី២២ កញ្ញា ១៩៩៥ ត្រង់កខាខណ្ឌពីទី ២-៥។ ករណីរឿងក្ដីរបស់ *Clive Ferreira និងគូរកន ទល់នឹង Allan No Levin និងគូរកន*, សំណុំរឿងលេខ CCT/5/95, សាលដីកា (តុលាការធម្មនុញ្ញានៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី៦ ធ្នូ ២០០៥ ត្រង់កថាខណ្ឌទី១៩៩។ *ករណីរឿក្ដីរបស់ ក្រុមចម្រុះជាតិដើម្បីគុណភាពរបស់មនុស្សខ្ទើយប្រុស និងខ្ទើយស្រី(National Coalition for Gay and Lesbian Equality) ទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹង បក្សពួក*, សំណុំរឿងលេខ CCT 10/99, សាលដីកា (តុលាការធម្មនុញ្ញានៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី២ធ្នូ ១៩៩៩ ត្រង់កថាខណ្ឌពីទី ២១-២២។

នៅមុនរបាយការណ៍ស្ថាពរ ឬមុនពេលសេចក្តីសម្រេចត្រូវបានធ្វើឡើង ដោយសមត្ថកិច្ចថ្នាក់ក្រោម [62]។

៣១- ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាជូនជាមតិដើម្បីត្រេះរិះពិចារណាថា អំណះអំណាងទីបីនៃបណ្តឹងសាទុក្ខ ដែលទាក់ទងទៅនឹងបញ្ហាដែលកំពុងតែរង់ចាំការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺមិនទាន់ដល់ពេលត្រូវប្តឹងនៅឡើយទេ ហេតុដូចនេះគឺមិនអាចឲ្យទទួលយកបានឡើយ។

## IV. សេចក្តីសន្និដ្ឋាន

៣២- អាស្រ័យហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះ សូមឲ្យ៖

ក. សម្រេចថា បណ្តឹងសាទុកនេះ មិនអាចទទួលយកបានទាំងស្រុង និង

ខ. បដិសេធចោលនូវសំណើរបស់សហមេធាវីមេធាវីការពារក្តី ដែលសុំឲ្យធ្វើសវនាការជាសាធាណៈ និងដោយផ្ទាល់មាត់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | |

[62] សូមអានករណីរឿងក្តីរបស់ *Srinivas Gundluri ទល់នឹង ក្រុមហ៊ុនសំណង់ស្ថាមពលអគ្គិសនី SEPCO Electric Power Construction*, សំណុំរឿងលេខ Appeal 1377, សាលដីកា (តុលាការកំពូលនៃប្រទេសឥណ្ឌា), ចុះថ្ងៃទិ៣០ កក្កដា ២០១០ ត្រង់កថាខណ្ឌទី២ ។ ករណីរឿងក្តីរបស់ *S.K. JHA Commodre ទល់នឹង រដ្ឋ Kerala និងបក្សពួក*, សំណុំរឿងឧទ្ធរណ៍លេខ 1017, ដីកាសម្រេច (តុលាការកំពូលនៃប្រទេសឥណ្ឌា) ចុះថ្ងៃទី១១ មករា ២០១១ នៅក្នុង 1 *Supreme Court Reporter* 295, ត្រង់ទំព័រ ២៩៦។